របាយការណ៍សង្ខេបស្តីពីការអនុវត្ត

# ៥ ឆ្នាំ

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព

# ២០១៤-២០១៨



# ក្រុមការងាររៀបចំ

## នាយកគណៈគ្រប់គ្រង

១. ឯកឧត្តម **ងឹម ច័ន្ទមករា**
អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក.ស.ជ.

## គណៈគ្រប់គ្រង

១. លោកជំទាវ **ប្រាក់ ថាវៈតារី**
២. ឯកឧត្តម **អ៊ុំ សម្បត្តិ**
៣. ឯកឧត្តម **នេត អ៊ុន**
៤. ឯកឧត្តម **ស្រី ចាន់**
៥. លោកជំទាវ **អ៊ឹង វណ្ណឫទ្ធី**

## គណៈកម្មការត្រួតពិនិត្យ

១. លោកស្រី **មាស រត្ថា**
២. លោក **អៀម សារ៉ាត**
៣. លោក **ហុក លី**
៤. លោក **ឈន អក្ខរា**
៥. លោក **យឿប ម៉ាលីណា**
៦. លោក **ចេក ចាន់នី**
៧. លោក **ទ័ន កុយ**
៨. លោក **សែម សុខបញ្ញា**

## ក្រុមការងារកសាងឯកសារ

១. លោក **វ៉ាន់ សុវិសាល**
២. លោក **កែវ សុភី**
៣. លោក **កែវ ច័ន្ទឧត្តម**
៤. លោក **ផន ចំរើន**
៥. លោក **ចាន់ ជ័យរិទ្ធ**
៦. លោក **ធី ថុនា**
៧. លោក **សុត មនោរម្យ**
៨. លោក **ទឹម សុភី**
៩. លោកស្រី **មាស ម៉ៅ**
១០. លោកស្រី **តាណា សោភ័ណ**

# ប្រភពឯកសារនិងរូបភាព

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រសួងមហាផ្ទៃ
ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់
ក្រសួងសុខាភិបាល
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ក្រសួងអប់រំ យុវជន និងកីឡា
ក្រសួងកិច្ចការនារី
ក្រសួងធម្មការ និងសាសនា
ក្រសួងទេសចរណ៍
កាកបាទក្រហមកម្ពុជា
ក្រុមប្រឹក្សាសកម្មភាពជនពិការ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
មូលនិធិជនពិការ
កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ
ផេកផ្លូវការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
ភ្នាក់ងារជាតិមុខរបរ និងការងារ
សមាគមតន្ត្រីសំនៀងជនពិការ
សមាគមនិងវិទ្យុសំឡេងជនពិការភ្នែក
ក្រុមហ៊ុន រាធីកា ឯ.ក. ឯកទេសថតរូបនិងវីដេអូ

ឧបត្ថម្ភការបោះពុម្ពដោយ ៖

ឧបត្ថម្ភការថតរូបដោយ ៖



ការបោះពុម្ពផ្សាយដោយក្រុមប្រឹក្សាសកម្មភាពជនពិការ
សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
រក្សាសិទ្ធិគ្រប់យ៉ាង© ឆ្នាំ២០១៩
បោះពុម្ពនៅរាជធានីភ្នំពេញ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
គឺជាមហាវីរៈបុរសខ្មែរស្នេហាជាតិ មាតុភូមិ និងប្រជាជន
ជាបិតាស្ថាបនិកសន្តិភាពនិងការអភិវឌ្ឍនៅកម្ពុជា



ជនមានពិការភាពកម្ពុជាទូទាំងប្រទេសសូមគោរពដឹងគុណ
ចំពោះគុណូបការៈដ៏ខ្ពង់ខ្ពស់ដែលមិនអាចកាត់ថ្លៃបាន
របស់សម្តេចតេជោនិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតជានិច្ចនិរន្ត។



ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

ក្រុមប្រឹក្សាសកម្មភាពជនពិការ
DISABILITY ACTION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ជាឯកសារដ៏មានតម្លៃបានកត់ត្រាទុកពីសមិទ្ធផលនៃវិស័យពិការភាពរយៈពេល ៥ឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ** ដែលបានខិតខំបំពេញភារកិច្ចជាប្រវត្តិសាស្ត្រសម្រាប់ជនមានពិការភាពទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះ យើងទាំងអស់គ្នាទទួលស្គាល់កត្តាសន្តិភាពនៅកម្ពុជាក្នុងពេលកន្លងមក បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍប្រទេសជាតិនិងលើកកម្ពស់សិទ្ធិមនុស្ស ពិសេសសិទ្ធិជនមានពិការភាពស្របតាមអនុសញ្ញានៃអង្គការសហប្រជាជាតិ សំដៅធ្វើឱ្យគុណភាពជីវិតរបស់ជនមានពិការភាពកាន់តែប្រសើរឡើង ព្រមទាំងបានចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរ រួមទាំងការដាក់បញ្ចូលបញ្ហាពិការភាពក្នុងគ្រប់វិស័យ។

តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨នេះ ជីវភាពរស់នៅនិងកំណើនការងាររបស់ជនមានពិការភាពត្រូវបានផ្តល់អាទិភាពសមរម្យនិងមានភាពជាម្ចាស់ការ។ ទន្ទឹមនឹងនេះ ការផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងសមធម៌ ព្រមទាំងការស្តារលទ្ធភាពពលកម្មកាយសម្បទានិងសតិបញ្ញាក៏ត្រូវបានរដ្ឋយកចិត្តទុកដាក់ផ្តល់ជូន។ កិច្ចអន្តរាគមន៍សេវាយុត្តិធម៌កាត់បន្ថយ និងឈានទៅរកការលុបបំបាត់ការរើសអើង ការរំលោភបំពាន ការប្រមាថ និងការកេងប្រវ័ញ្ចលើជនមានពិការភាពត្រូវបានលើកកម្ពស់ការយល់ដឹងនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយ ព្រមទាំងបានចាត់វិធានការណ៍យ៉ាងមានប្រសិទ្ធភាពលើការទប់ស្កាត់ការធ្វើទារុណកម្មឬអំពើឃោរឃៅយង់ឃ្នង និងអយុត្តិធម៌ អាប់ឱន កិត្តិយស និងដាក់ទណ្ឌកម្ម ពិសេសលើស្ត្រីនិងកុមារមានពិការភាព។

លើសពីនេះទៅទៀត ជនមានពិការភាពទទួលបានការធានាសេវាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយគុណភាពនិងសមធម៌ រួមទាំងការបង្កើននូវសម្ភារៈសិក្សាដែលជាការផ្តល់ឱកាសក្នុងការអភិវឌ្ឍខាងបញ្ញា សិល្បៈ និងគំនិតច្នៃប្រឌិតរបស់ជនមានពិការភាព មិនត្រឹមតែដើម្បីផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងដើម្បីភាពសម្បូរបែបរបស់សង្គមទៀតផង។ រាជរដ្ឋាភិបាលកម្ពុជាតែងបានលើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងការសម្តែងមតិ ទទួលព័ត៌មាន និងចូលរួមជីវភាពនយោបាយ ព្រមទាំងជីវភាពសង្គម។



អាសយដ្ឋានៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ
អ៊ីមែលៈ dac@dac.org.kh គេហទំព័រៈ www.dac.org.kh
Address: MoSVY, #788 Monivong Blvd., Phnom Penh
ទូរស័ព្ទៈ (855) 23 727 428
ទូរសារៈ (855) 23 727 426

កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានបង្កឱកាសដល់ជនមានពិការភាពបានចូលរួមនូវសកម្មភាពសង្គមរួមមានវប្បធម៌ សាសនា កីឡា សិល្បៈ ការលម្ហែ និងសកម្មភាពផ្សេងៗទៀត ព្រមទាំងបានកែសម្រួលនិងអភិវឌ្ឍនូវបរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនបម្រើជាសាធារណៈ ចំណេះដឹង ព័ត៌មាន និងការទំនាក់ទំនងដែលជាការបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាពទទួលបានសិទ្ធិពេញលេញ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រុមប្រឹក្សាសកម្មភាពជនពិការនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការរបស់ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ពិសេសជនមានពិការភាពខ្លួនឯងផ្ទាល់ដែលបានចូលរួមយ៉ាងសកម្មធ្វើឱ្យផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ទទួលបានជោគជ័យគួរជាទីមោទនៈ និងបានផ្តល់ផលប្រយោជន៍យ៉ាងពិតប្រាកដដល់ជនមានពិការភាពនៅកម្ពុជា។

ថ្ងៃ ចន្ទ ៧រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

**ជ.ក្រុមប្រឹក្សាសកម្មភាពជនពិការ**

**ប្រធាន**

**វង សូត**

# សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ត្រូវបានប្រកាសដាក់ឱ្យប្រើជាផ្លូវការកាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៤ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ។** ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនេះ ត្រូវបានចាត់ទុកជាឧបករណ៍គោលនយោបាយជាថាមវន្តដែលបានទាមទារឱ្យមានការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងកែលម្អជាប្រចាំ ឆ្លើយតបទៅនឹងសកម្មភាពជាក់ស្តែងនៃវិស័យពិការភាពក្នុងរយៈពេល៥ឆ្នាំកន្លងមក។

ការដោះស្រាយជាក់លាក់និងបទពិសោធល្អៗ សម្រាប់រួមចំណែកដល់កសាងសមត្ថភាពនៃការអនុវត្តវិស័យពិការភាព ត្រូវបានជំរុញសង្គមកម្ពុជាបោះជំហានឆ្ពោះទៅរកការលុបបំបាត់ឧបសគ្គនានា និងផ្តល់ឱកាសដល់ជនមានពិការភាពចូលរួមដើម្បីប្រែក្លាយសង្គមមួយដើម្បីយើងទាំងអស់គ្នា។

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២ ០ ១ ៤ - ២ ០ ១ ៨ នាពេលកន្លងមកបានប្រើប្រាស់អភិក្រមដែលផ្អែកលើកម្មវិធីធានាឱ្យមានការសម្របសម្រួលជាយុទ្ធសាស្ត្រ និងការចាត់អាទិភាពនូវសកម្មភាពនានា។ ក្រៅពីការរៀបចំកម្មវិធីដោយផ្អែកលើបញ្ហាដែលនាំឱ្យមានពិការភាពសកម្មភាពនានាដែលជំរុញនិងគាំទ្រដល់ការពង្រឹងបន្ថែមនូវកាលានុវត្តភាពនានា ក៏ដូចជាការពង្រីកនូវអត្ថប្រយោជន៍ និងផលចំណេញបន្ថែមសម្រាប់សង្គម ពិសេសសម្រាប់ផលប្រយោជន៍របស់ជនមានពិការភាពត្រូវបានយកមកអនុវត្ត។

កន្លងមករាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញអំពីឆន្ទៈនយោបាយ ការប្តេជ្ញាចិត្តដ៏រឹងមាំរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម ពិសេសការបញ្ចូលជនមានពិការភាពទៅកិច្ចអភិវឌ្ឍសម្រាប់សង្គមជាតិ និងពិភពលោកទាំងមូល។

ប្រទេសកម្ពុជា មានយន្តការសម្រាប់ដោះស្រាយផលលំបាករបស់ជនមានពិការភាពដែលយន្តការទាំងនោះបាននិងកំពុងយកចិត្តទុកដាក់អនុវត្ត បម្រើឱ្យផលប្រយោជន៍របស់បងប្អូនជនមានពិការភាពប្រកបដោយប្រសិទ្ធិភាព។ បើទោះបីជាការលើកកម្ពស់ ផ្តល់លទ្ធភាពទទួលបានសេវាពិការភាព និងការអភិវឌ្ឍសេវានៅតែមានកម្រិត និងជាក្តីកង្វល់របស់បងប្អូនជនមានពិការភាព ប៉ុន្តែរាជរដ្ឋាភិបាលមានឆន្ទៈនិងការប្តេជ្ញាចិត្តធ្វើការកែទម្រង់ស្ថាប័ន និងវិធីសាស្ត្រដោះស្រាយដែលបង្កនូវលក្ខណៈងាយស្រួលដល់បងប្អូនមានពិការភាព តាមរយៈការផ្ទេរបច្ចេកវិទ្យា កំណែទម្រង់ច្បាប់ និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដើម្បីឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ជនមានពិការភាព។

ជនមានពិការភាព គឺជាមនុស្សដែលត្រូវបានយកចិត្តទុកដាក់ និងមានសិទ្ធិដូចជនមិនមានពិការភាពដែរ។ ជនមានពិការភាពនិងកុមារមានពិការភាពត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់សកម្មភាពអភិវឌ្ឍមិនត្រូវទុកជនមានពិការភាពឱ្យនៅដាច់ដោយឡែកនោះទេ។ ត្រូវធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថ ការយល់ឃើញរបស់សង្គមចំពោះជនមានពិការភាព ក្នុងការទទួលស្គាល់សកម្មភាព និងសំឡេងរបស់ជនមានពិការភាពដែលនាំមកនូវការលើកកម្ពស់ដល់ការអភិវឌ្ឍសង្គម។ ជនមានពិការភាពនិងកុមារមានពិការភាព មានសមត្ថភាពគ្រប់គ្រាន់ក្នុងការយកឈ្នះនូវរាល់ឧបសគ្គរាំងផ្សេងៗដោយខ្លួនឯង ដូចនេះ ការដាក់បញ្ចូលពួកគេទៅក្នុងគ្រប់វិស័យដោយផ្អែកលើគោលការណ៍សិទ្ធិស្មើគ្នាដើម្បីធ្វើឱ្យជីវិតពួកគេនិងគ្រួសារមានភាពប្រសើរឡើង៕

# ទិសដៅយុទ្ធសាស្ត្រ
# ទី១



## កាត់បន្ថយភាពក្រីក្ររបស់ជនមានពិការភាព តាមរយៈការលើកកម្ពស់កំណើនការងារនិងអាជីពសមស្របសម្រាប់ជនមានពិការភាពដើម្បីបង្កើនជីវភាពរស់នៅសមរម្យនិងពង្រឹងភាពជាម្ចាស់ការ

# សមិទ្ធផលសម្រេចបាន



ជនមានពិការភាពគ្រប់រូបមានសិទ្ធិរស់រានមានជីវិតចាប់តាំងពីកំណើត និងមានសិទ្ធិទទួលបានការការពារចាំបាច់ដើម្បីធានាបាននូវសិទ្ធិស្មើភាពជាមួយអ្នកដទៃ។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ចំពោះសុខទុក្ខ និងគិតគូរដល់ជីវភាពរស់នៅរបស់ជនមានពិការភាព ទាំងនៅទីជនបទដាច់ស្រយាលនិងទីក្រុង ជាក់ស្តែង ជនមានពិការភាពចំនួន១១.៦២៨នាក់ក្នុងរាជធានី ខេត្ត ចំនួន១០ទូទាំងប្រទេសបានទទួលរបបគោលនយោបាយតាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការលើកកម្ពស់ជីវភាពជនមានពិការភាព និងគ្រួសាររបស់ពួកគេឱ្យផុតពីភាពក្រីក្រគឺជាការរួមចំណែកឈានទៅសម្រេចបាននូវកំណើននៃបរិយាបន្នវិស័យពិការភាពទៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។

# អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៣អនក្រ.បក

អនុក្រឹត្យ
ស្តីពី
របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា




ប័ណ្ណសង្គមកិច្ចផ្តល់ជូនដល់ជនមានពិការភាព ដើម្បីទទួលបានរបបគោលនយោបាយ

- បានអនុវត្តនៅក្នុងរាជធានីខេត្តចំនួន១០ ទូទាំងប្រទេស
- ជនមានពិការភាពចំនួន១១.៦២៨នាក់ បានទទួលរបបគោលនយោបាយ

## តំបន់ប្រតិបត្តិកម្មវិធីផ្តល់របបគោលនយោបាយ ២០១៨





ជនមានពិការភាព មានឱកាសជ្រើសរើសទីតាំងលំនៅដ្ឋាននិងអ្នកដែលត្រូវរស់នៅជាមួយដោយឈរលើមូលដ្ឋានស្មើភាពគ្នា ដោយមិនត្រូវបានគេបង្ខំឱ្យរស់នៅតាមការរៀបចំជាពិសេសណាមួយឡើយ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សេវាគាំទ្រដល់ការរស់នៅផ្តល់កន្លែងស្នាក់អាស្រ័យ និងសេវាសហគមន៍ផ្សេងៗទៀតដល់ជនមានពិការភាព និងអតីតយុទ្ធជនមានពិការភាព ដើម្បីជួយឱ្យជនមានពិការភាពមានសិទ្ធិរួមបញ្ចូលទាំងការចូលរួមយ៉ាងពេញលេញរបស់ជនមានពិការភាពនៅសហគមន៍។

គិតពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានដោះស្រាយរាល់ការលំបាករបស់អតីតយុទ្ធជន និងយោធិនមានពិការភាពជាក់ស្តែង រដ្ឋបានសាងសង់ផ្ទះជូនអតីតយុទ្ធជនមានពិការភាពចំនួន២.៩៦៥ខ្នង។

**ក. សមាគមអតីតយុទ្ធជន**

- មណ្ឌលយោធិនពិការភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យ ចំនួន ៤០០ខ្នង
- មណ្ឌលយោធិនពិការគូលែន ខេត្តសៀមរាប ចំនួន ២៤៧ខ្នង
- មណ្ឌលយោធិនពិការតាកែនកោះស្លា ខេត្តកំពត ចំនួន ៣៥៧ខ្នង
- សមាគមអតីតយុទ្ធជនរាជធានី ខេត្ត ចំនួន ៨០ខ្នង។

**ខ. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានសាងសង់ផ្ទះ ចំនួន ២០១ខ្នង។

**គ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានសាងសង់ផ្ទះ ចំនួន ១.៦៨០ខ្នង។





## អនុក្រឹត្យលេខ១០៨ អនក្រ.បក ស្តីពីការកំណត់អត្រានិងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

សិទ្ធិទទួលបានការងារ និងឱកាសចិញ្ចឹមជីវិតឈរលើទីផ្សារការងារ ព្រមទាំងបរិយាកាសការងារបើកទូលាយសម្រាប់ជនមានពិការភាពត្រូវបានទទួលស្គាល់ និងយកចិត្តទុកដាក់ជំរុញពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ហើយបានហាមឃាត់ការរើសអើងដោយសារតែពិការភាពចំពោះគ្រប់បញ្ហាដែលទាក់ទិននឹងរាល់ទម្រង់នៃការងារ រួមទាំងលក្ខខណ្ឌនៃការជ្រើសរើស ការជួល ការបម្រើការងារ ការបន្តការងារ ការអភិវឌ្ឍមុខរបរ និងលក្ខខណ្ឌការងារដែលមានសុវត្ថិភាព និងជាសុខភាព។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី








### ចំនួនជនមានពិការភាពបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋនិងវិស័យឯកជន គិតត្រឹមឆ្នាំ២០១៨

- ស្ថាប័នរដ្ឋ
- វិស័យឯកជន

ស្ថាប័នរដ្ឋ ចំនួន៤០ បានជ្រើសរើសជនមានពិការភាពចូលបម្រើការងារ

វិស័យឯកជន ចំនួន៧៧ បានជ្រើសរើសជនមានពិការភាពចូលបម្រើការងារ





ការកែលម្អជីវភាពរស់នៅធានាដល់ការកាត់បន្ថយភាពក្រីក្ររបស់ជនមានពិការភាព ការលើកកម្ពស់ការងារ ព្រមទាំងមុខរបរសមរម្យត្រូវបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា ទន្ទឹមនឹងនេះការផ្តល់ជំនួយឧបត្ថម្ភពីរដ្ឋត្រូវបានអនុវត្តជាបន្តបន្ទាប់តាមរយៈការផ្តល់របបគោលនយោបាយ។ ក្រៅពីនេះសប្បុរសជន និងសង្គមស៊ីវិល ព្រមទាំងដៃគូអភិវឌ្ឍក៏បានចូលរួមចំណែកទាំងធនធានថវិកា និងធនធានមនុស្សដើម្បីសម្រេចបាននូវឧត្តមប្រយោជន៍សម្រាប់ជនមានពិការភាព។



ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ត្រូវបានប្រកាសដាក់ឱ្យប្រើជាផ្លូវការ និងបានកំណត់ជាយុទ្ធសាស្រ្តដាក់ឱ្យដំណើរការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនមានពិការភាព និងការពង្រឹងការលើកកម្ពស់សុខុមាលភាពជនមានពិការភាព ។








## ករណីសិក្សា : ភាពជោគជ័យរបស់ជនមានពិការភាព

### ភាពតស៊ូរបស់ជនមានពិការភាពភ្នែកទាំងសងខាងរហូតក្លាយជាអគ្គនាយកស្ថានីយវិទ្យុ

លោក នាង សារិទ្ធ វ័យ៣៦ឆ្នាំ មានស្រុកកំណើត នៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ គាត់ពិការភ្នែក ទាំងសងខាងដោយសារជំងឺនៅឆ្នាំ១៩៨៤។ បើទោះបី ជា **សារិទ្ធ** ពិការភ្នែកទាំងសងខាងក៏ដោយ ប៉ុន្តែទឹកចិត្ត មិនពិការទេ **សារិទ្ធ** បានប្រឹងប្រែងតស៊ូរៀនសូត្រនៅសាលា ពិការភ្នែក និងគ-ថ្លង់នៃអង្គការគ្រួសារថ្មីរហូតបានបញ្ចប់ ថ្នាក់ទី១២ទទួលបានសញ្ញាបត្រទុតិយភូមិនៅឆ្នាំ២០១០ និងបន្តរៀនសូត្រនៅសាលាភូមិន្ទវិចិត្រសិល្បៈដោយ ចេះប្រគំឧបករណ៍តន្ត្រីជាច្រើន ពិសេសជំនាញចាប៉ីដងវែង។

ដោយភាពអំណត់ និងការតស៊ូពុះពាររាល់ឧបសគ្គ ក្រោមការជួយសណ្តោសប្រណីពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សារិទ្ធ** បានទទួលក្របខណ្ឌរដ្ឋបម្រើការងារ នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានតួនាទីជាសមាជិកក្រុម លេខាសម្តេចតេជោ នាយករដ្ឋមន្ត្រីមាន ឋានៈស្មើ**ប្រធាននាយកដ្ឋាន**។ បច្ចុប្បន្ន **សារិទ្ធ** ជាអគ្គនាយកស្ថានីយវិទ្យុ សំឡេងសុភមង្គលដែលជាវិទ្យុតំណាងឱ្យជនមានពិការភាព។

### សមត្ថភាពរបស់ជនមានពិការភាពគ្រប់គ្រងសហគ្រាសផលិតនំ



មជ្ឈមណ្ឌលជីវិតរស់នៅដោយឯករាជ្យនៃ ជនពិការភ្នំពេញ បានក្លាយជាអង្គការសហគ្រិនភាពគំរូសម្រាប់ជនមានពិការភាព នៅប្រទេសកម្ពុជា។ គម្រោង“**កែលម្អសហគមន៍**”បានទទួលការគាំទ្រពីក្រុមប្រឹក្សាសកម្មភាពជនពិការ និង មជ្ឈមណ្ឌលអភិវឌ្ឍជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ក្នុងការលើកកម្ពស់ និងគាំទ្រ ផលិតផលរបស់បងប្អូនមានពិការភាព ដែលជាអាជីវករ សិប្បករ ផលិតករ និងអ្នកផ្តល់សេវាចូលរួមយ៉ាងពេញលេញប្រកបដោយភាពប្រកួតប្រជែងលើទីផ្សារសេរី។ គម្រោងកែលម្អសហគមន៍ត្រូវបានរៀបចំឡើង ស្របតាមគោលនយោបាយជាតិស្តីពីភូមិមួយ ផលិតផលមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។





មជ្ឈមណ្ឌលជីវិតរស់នៅដោយឯករាជ្យនៃជនពិការភ្នំពេញមានរោងចក្រផលិតនំតាមស្តង់ដាប្រទេសជប៉ុនដែល មានផ្លាកយីហោនំឈ្មោះ ”**ក្រយ៉ាខ្មែរ**” បានផ្តល់ឱកាសការងារ និងប្រាក់ចំណូលដល់ជនមានពិការភាព។



យោងតាមទិន្នន័យការអង្កេតសេដ្ឋកិច្ចនិងសង្គម ឆ្នាំ២០១៤ ប្រទេសកម្ពុជាមានប្រជាជនដែលមានពិការភាព ចំនួន៥២៤.០០០នាក់ ស្មើនឹង៤ភាគរយ នៃប្រជាជនកម្ពុជាសរុប។ អត្រាគ្មានការងារធ្វើរបស់ជនមានពិការភាពស្ថិតក្នុងកម្រិត ៦,៣២ភាគរយ។ អត្រាគ្មានការងារធ្វើចំពោះជនមានពិការភាព នៅទីក្រុងមាន៣,២២ភាគរយ ធៀបនឹង ១,៤៩ភាគរយនៅជនបទ។

# ទិសដៅយុទ្ធសាស្ត្រ
# ទី២









## ផ្តល់ដល់ជនមានពិការភាព
## នូវសេវាសុខភាពប្រកបដោយ
## គុណភាព និងសមភាព
## ព្រមទាំងការស្តារលទ្ធភាពពលកម្ម
## កាយសម្បទានិងសតិបញ្ញា




# សមិទ្ធផលសម្រេចបាន

## ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលជំហានទី៣ ឆ្នាំ២០១៦-២០២០

ក្រសួងសុខាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលជំហានទី៣ ឆ្នាំ២០១៦-២០២០បង្ហាញពីចក្ខុវិស័យ“លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃវិស័យសុខាភិបាលដោយឈរលើគុណតម្លៃសិទ្ធិ សុខភាព និងសមធម៌សម្រាប់ប្រជាពលរដ្ឋគ្រប់រូបរួមទាំងជនមានពិការភាព”។ ផែនការយុទ្ធសាស្ត្របានដាក់ចេញនូវអនុសាសន៍ ពង្រីកកម្មវិធីមូលនិធិសមធម៌ដើម្បីបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុដល់ជនងាយរងគ្រោះដូចជាជនមានពិការភាព មនុស្សចាស់ជរា និងកុមារអាយុក្រោម៥ឆ្នាំ។

កម្មវិធីមូលនិធិសមធម៌កំពុងត្រូវបានអនុវត្តទូទាំងប្រទេសដោយបានគ្របដណ្តប់ដល់ប្រជាជនក្រីក្រប្រមាណ២,៦លាននាក់ ដោយរួមបញ្ចូលជនមានពិការភាព។




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

"អ្នកជំងឺក្រីក្រនិងជនមានពិការភាព ត្រូវបានបង់ថ្លៃសេវាពិនិត្យនិងព្យាបាល ជួសដោយរាជរដ្ឋាភិបាល"



ក្រសួងសុខាភិបាលបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីចូលរួមនិងធានាដល់ការផ្តល់សេវាជូនដល់ជនមានពិការភាពប្រកបដោយគុណភាពនិងសមធម៌ ការពង្រឹងនិងពង្រីកសកម្មភាពពិនិត្យព្យាបាលជំងឺដល់ជនមានពិការភាពនិងចាស់ជរាដែលមានជីវភាពលំបាកដោយឥតគិតថ្លៃនៅគ្រប់មូលដ្ឋានសុខាភិបាលដូចជាមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត។



រាជរដ្ឋាភិបាលកម្ពុជាបានសហការជាមួយដៃគូអភិវឌ្ឍផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាគ្រប់ប្រភេទដោយឥតគិតថ្លៃដល់ជនមានពិការភាពសរុបចំនួន១០៧.៣៣៣នាក់ ស្ត្រីចំនួន២៦.៨៦៣នាក់ និងបានផ្តល់សេវាស្តារវេជ្ជសាស្ត្របានចំនួន២១៥.០៨៨នាក់ ស្ត្រីចំនួន១១៨.៣៤១នាក់គិតត្រឹមឆ្នាំ២០១៨។ រដ្ឋបានផ្តល់ការឧបត្ថម្ភប្រាក់ថ្លៃអាហារនិងសោហ៊ុយធ្វើដំណើរទៅមកដល់ជនមានពិការភាពសរុបចំនួន៣២២.៤២១នាក់ ស្ត្រី១៤៥.២០៤នាក់។

## ស្ថិតិជនមានពិការភាពមកទទួលសេវាស្តារលទ្ធភាពពលកម្មនៅមជ្ឈមណ្ឌលស្តារលទ្ធភាពកាយសម្បទា

តារាងរបាយការណ៍សេវាកម្មនៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន១១កន្លែង

| មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ចំនួន១១កន្លែង | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| ជនមានពិការភាពដែលបានចុះបញ្ជីសរុប | ២៦.២០៣ | ២៦.៩២០ | ២៦.៤៩០ | ២៦.២៤៣ | ២៧.២៦៤ |
| ជនមានពិការភាពជាស្ត្រីដែលបានចុះបញ្ជី | ៧.១៥៧ | ៦.៧០៩ | ៦.៥៩០ | ៦.៧៩៨ | ៧.០៥៦ |
| ជនមានពិការភាពថ្មីដែលបានចុះបញ្ជីសរុប | ៣.៤៩៩ | ៣.៧០២ | ៣.៧៧៤ | ៣.៥៩៥ | ៣.២០១ |
| ឧបករណ៍អវយវៈសិប្បនិម្មិតនិងរណប | ៧.១២៦ | ៧.១៦១ | ៧.១១០ | ៦.៩៩២ | ៦.៣៨១ |
| រទេះរុញ | ១.១៣៩ | ១.១៤៥ | ១.២១០ | ១.៣១២ | ១.៣៤៣ |
| ឧបករណ៍ជំនួយដ៏ទៃទៀត | ២.៧៥៧ | ៣.៨៧៦ | ៣.១៦៤ | ២.០៨៤ | ១.៨៣៩ |
| ការជួសជុលឧបករណ៍ជំនួយ | ១២.០៥៧ | ១៣.០៥៥ | ១៣.៤៥៤ | ១២.៧៩៥ | ១៤.៥៧១ |



# ករណីសិក្សា : ការទទួលបានសេវាថែទាំសុខភាព និងស្តារលទ្ធភាពពលកម្ម



ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី៣ បានដាក់បញ្ចូលនូវគោលដៅទាក់ទងទៅនឹងជនមានពិការភាព រួមទាំងការផ្តល់សេវាស្តារលទ្ធភាពពលកម្មធ្ងន់ធ្ងរ បណ្តោះអាសន្ន និងរយៈពេលវែង បង្កើនការទទួលបានសេវាសុខភាពផ្លូវចិត្ត កាត់បន្ថយពិការភ្នែកនៅតំបន់ងាយរងគ្រោះ និងផ្តល់សេវាសម្រាប់អ្នកដែលមានភាពចុះខ្សោយនៃការស្តាប់ ហើយថវិកាចំនួន១,១២លានដុល្លារត្រូវបានបែងចែកដើម្បីអនុវត្តនូវអាទិភាពទាំងនេះ។



ការផ្ទេរការគ្រប់គ្រងទាំងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុទាំងស្រុងសម្រាប់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាពីអង្គការដៃគូអភិវឌ្ឍ មករាជរដ្ឋាភិបាលកម្ពុជាគឺជាការបង្ហាញនូវឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការធានានូវនិរន្តរភាពនៃការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាដល់ជនមានពិការភាព។ រាជរដ្ឋាភិបាលបានបង្កើនថវិការដ្ឋសម្រាប់ទ្រទ្រង់សេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទាពីចំនួន ៧៦៥.៤៤៧ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៣ រហូតដល់១.១៥៦.១៨០ដុល្លារអាមេរិកក្នុងឆ្នាំ ២០១៦ ពោលគឺមានការកើនឡើងប្រមាណ៥១%។



# ទិសដៅយុទ្ធសាស្ត្រ
# ទី៣

## បង្កើនកិច្ចអន្តរាគមន៍សេវាយុត្តិធម៌ កាត់បន្ថយ និងឈានទៅរកការលុបបំបាត់ ការរើសអើង ការរំលោភបំពាន ការប្រមាថ និងការកេងប្រវ័ញ្ចលើជនមានពិការភាព








ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ បានការពារសិទ្ធិ និងសេរីភាពរបស់ជនមានពិការភាព។ ការទប់ស្កាត់ ការកាត់បន្ថយ និងលុបបំបាត់ការរើសអើង ដើម្បីធានាថាជនមានពិការភាពអាចចូលរួមបានពេញលេញ និងស្មើភាពក្នុងសកម្មភាពសង្គម។ ជំពូកទី១២ មាត្រា៥០ ដល់មាត្រា៥៣នៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការក៏បានការពារដល់សិទ្ធិសេរីភាពនិងសន្តិសុខរបស់ជនមានពិការភាពផងដែរដូចជា ការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលទុច្ចរិតក្នុងការ មិនផ្តល់សិទ្ធិសេរីភាព ដល់ជនមានពិការភាព។ សិទ្ធិសេរីភាព និងសន្តិសុខបុគ្គល ត្រូវបានការពារដោយក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។



# សមិទ្ធផលសម្រេចបាន

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការទទួលបានសេវាយុត្តិធម៌សម្រាប់ជនមានពិការភាព



រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តរួមគ្នាជាមួយនឹងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ “ការទទួលបានសេវាយុត្តិធម៌សម្រាប់ជនមានពិការភាព”។ កម្មវិធីត្រូវបានផ្តួចផ្តើមដោយមានកិច្ចពិភាក្សារវាងតំណាងក្រសួងយុត្តិធម៌តំណាងក្រុមប្រឹក្សាសកម្មភាពជនពិការ រាជធានី-ខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត អង្គការតំណាងជនមានពិការភាព អង្គការជាតិ-អន្តរជាតិ ដៃគូពាក់ព័ន្ធ និងជនមានពិការភាពច្រើនប្រភេទ។

## គោលនយោបាយជាតិស្តីពីជំនួយផ្លូវច្បាប់



ក្រសួងយុត្តិធម៌បានរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីជំនួយផ្លូវច្បាប់ ក្នុងគោលបំណងការពារប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះដែលពុំមានលទ្ធភាពស្វែងរកសេវាការពារក្តីនៅតុលាការនឹងទទួលបាននូវមេធាវីការពារក្តីប្រកបដោយយុត្តិធម៌។ ដើម្បីកំណែទម្រង់ក្នុងប្រព័ន្ធតុលាការនៅកម្ពុជាកាន់តែល្អប្រសើរក្នុងការផ្តល់ជំនួយផ្នែកច្បាប់តាមរយៈការទម្លាក់ថវិកាឱ្យក្រសួងយុត្តិធម៌លើប្រតិបត្តិការការពារក្តីជូនជនក្រក្រីនិងជនមានពិការភាព ជាការបង្ហាញពីឆន្ទៈនៃការកែទម្រង់ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

## ករណីសិក្សា : គម្រោងការទទួលបានសេវាយុត្តិធម៌សម្រាប់ជនមានពិការភាព

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានសហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិក្នុងការអនុវត្តគម្រោងទទួលបានសេវាយុត្តិធម៌សម្រាប់ជនមានពិការភាពដើម្បីលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការក្នុងការពង្រឹងសិទ្ធិទទួលបាននូវសេវាយុត្តិធម៌សម្រាប់ជនមានពិការភាព។ គម្រោងនេះបានសម្រេចជោគជ័យជាសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖



- បណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីយុត្តិធម៌ចំនួន៨២រូប ដើម្បីផ្តល់សេវាយុត្តិធម៌ដល់ជនមានពិការភាពប្រកបដោយប្រសិទ្ធភាព។
- បណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរាជការ និងបុគ្គលិកអង្គការជនពិការចំនួន២១៩នាក់ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាយុត្តិធម៌ដល់ជនមានពិការភាព។
- ពង្រឹងសមត្ថភាពអង្គការជនពិការស្តីពីការតាមដានករណីរំលោភសិទ្ធិជនមានពិការភាព ដើម្បីដើរតួជាអ្នកផ្តល់សេវាបញ្ជូន។
- មានករណីចំនួន៥៧ ត្រូវបានបញ្ជូនទៅរកសេវាជំនួយផ្នែកច្បាប់ ហើយជនមានពិការភាពប្រមាណ៨.០០០នាក់បានដឹងពីសេវាជំនួយផ្លូវច្បាប់ ដែលបានផ្សព្វផ្សាយតាមវិទ្យុ និងបណ្តាញសង្គម។



# ទិសដៅយុទ្ធសាស្ត្រ

# ទី៤

## ពង្រឹងនិងពង្រីកសេរីភាព សន្តិសុខបុគ្គល និងការគ្រប់គ្រងស្ថានភាពនៃហានិភ័យ ស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌ ក្នុងពេលមានគ្រោះមហន្តរាយដែលរួមបញ្ចូលជនមានពិការភាព









រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយតាមរយៈព្រះរាជក្រមលេខ នស / រកម / ០៧១៥ / ០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលមានគោលដៅ៖ (១). ត្រៀមបង្ការបន្សាំកាត់បន្ថយគ្រោះថ្នាក់ មុនពេលមានគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិឬមនុស្ស (២).ឆ្លើយតបសង្គ្រោះបន្ទាន់ ក្នុងពេលមានគ្រោះមហន្តរាយនិង (៣).ស្តារឡើងវិញមុននិងក្រោយ ពេលមានគ្រោះមហន្តរាយ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកាកបាទក្រហមកម្ពុជាបានធ្វើការជាមួយគ្នាយ៉ាងជិតស្និទដើម្បីអនុវត្ត សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយនៅទូទាំងប្រទេស ដោយមាន យន្តការសម្របសម្រួល និងឆ្លើយតបទាន់ពេលវេលា ហើយជនមានពិការភាពត្រូវបាន យកចិត្តទុកដាក់ជាក្រុមគោលដៅអាទិភាព។

# សមិទ្ធផលសម្រេចបាន

## ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៤-២០១៨



ការបង្កើនកិច្ចការពារនិងសុវត្ថិភាពដល់ជនមានពិការភាពក្នុងស្ថានភាពនៃហានិភ័យតាមរយៈការបណ្តុះបណ្តាល ការដាក់បញ្ចូលតម្រូវការ ការលើកកម្ពស់សេវា និងកម្មវិធីជួយទ្រទ្រង់ ការបង្កើនឧបករណ៍និងបច្ចេកវិទ្យាជំនួយសម្រាប់ជនមានពិការភាពដើម្បីពង្រឹងកាត់បន្ថយ និងសម្របសម្រួលដល់ជនមានពិការភាពក្នុងពេលមានហានិភ័យឬគ្រោះមហន្តរាយពីធម្មជាតិកើតឡើងត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។

គ្រួសារចំនួន៤.៤៨០គ្រួសារ ក្នុងនោះគ្រួសារដែលមានជនមានពិការភាពបានចូលរួមសកម្មភាពត្រៀមបង្ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍។

គ្រួសារចំនួន១០.៣០៦ រួមទាំងគ្រួសារជនមានពិការភាពបានទទួលជំនួយមនុស្សធម៌។

## ករណីសិក្សា : ការកសាងផែនការយុទ្ធសាស្ត្រសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ២០១៩-២០២៣ ប្រកបដោយបរិយាបន្ន



រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៩-២០២៣) ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកជាប់ពាក់ព័ន្ធ ដែលមានអ្នកតំណាងក្រុមងាយរងគ្រោះដូចជា ជនក្រីក្រ ស្ត្រីនិងជនមានពិការភាព។ ដំណើរការរៀបចំផែនការជាតិប្រកបដោយបរិយាបន្ននិងធានាឱ្យមានតំណាងរបស់ក្រុមជនងាយរងគ្រោះអាច នាំយកតម្រូវការនិងកង្វល់ទៅដល់អាជ្ញាធរ និងធ្វើជាអ្នកនាំសារទៅដល់ប្រជាជនដែលពិបាកក្នុងការទទួលបានព័ត៌មានអំពីហានិភ័យនៃគ្រោះមហន្តរាយ។ ជាលទ្ធផលយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ត្រូវបានបញ្ជ្រាបទៅក្នុងយុទ្ធសាស្ត្រតាមវិស័យនិងឆ្លើយតបទៅនឹងភាពងាយរងគ្រោះនិងតម្រូវការជាក់ស្តែងរបស់ជនងាយរងគ្រោះ។

## បរិយាបន្នពិការភាពទៅក្នុងបម្រែបម្រួលអាកាសធាតុ

រាជរដ្ឋាភិបាលបានកំពុងសហការរៀបចំគម្រោងបរិយាបន្នពិការភាពទៅក្នុងបម្រែបម្រួលអាកាសធាតុ ដែលនឹងត្រូវអនុវត្តរយៈពេលប្រាំឆ្នាំចាប់ពីឆ្នាំ២០១៩ ដល់២០២៤ ដោយផ្តោតលើខេត្តគោលដៅចំនួនប្រាំបួនខេត្តដែលងាយរងឥទ្ធិពលពីការបម្រែបម្រួលអាកាសធាតុ និងមានចំនួនប្រេវ៉ាឡង់ជនមានពិការភាពច្រើន។ គម្រោងត្រូវបានផ្តួចផ្តើមឡើងដោយផ្តោតលើការអនុវត្តគោលនយោបាយ ការកសាងសមត្ថភាព និងប្រព័ន្ធផ្តល់ព័ត៌មានជាមុនប្រកបដោយបរិយាបន្ន។





# ផ្តល់អាទិភាព និងសិទ្ធិអំណាច
# ដល់ជនមានពិការភាព
# លើគ្រប់វិស័យដើម្បីគ្មានពិការភាព



ទិសដៅយុទ្ធសាស្ត្រ

# ទី ៥

## ធានាថាជនមានពិការភាពអាចមានលទ្ធភាពទទួលបានសេវាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយគុណភាពនិងសមភាព



យោងតាមមាត្រា៦៨នៃរដ្ឋធម្មនុញ្ញកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់កិច្ចការអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៅសាលា រៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយ ឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំ យ៉ាងតិចប្រាំបួនឆ្នាំ។ ក្នុងចំណោម កុមារមានពិការភាពអាយុ៦ឆ្នាំដល់១៤ឆ្នាំ ប្រហែលជា៧០%បានចូលរៀន។ សមាមាត្រនៃអ្នកដែលបានបញ្ចប់បឋមសិក្សា មានអត្រាប្រហាក់ប្រហែល គ្នាក្នុងចំណោមប្រជាជនមានពិការភាពនិងមិនមានពិការភាព( ៤៧%និង៥២% )។ ប្រហែលពាក់កណ្តាលនៃជនមានពិការភាពបានបញ្ចប់បឋមសិក្សា និងឈានទៅបញ្ចប់មធ្យមសិក្សា( ១៦%និង ៣០% )។

# សមិទ្ធផលសម្រេចបាន

## ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨




ផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈកាន់តែស៊ីជម្រៅ និងមុតស្រួចក្នុងបរិបទកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាពស្របតាមដំណើរការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា និងមានចក្ខុវិស័យ កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពគុណធម៌ តាមរយៈ ៖

- ធានាការអប់រំប្រកបដោយសមធម៌ បរិយាបន្ន លើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។
- ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

# ការទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ របស់ជនមានពិការភាព







## កម្មវិធីសាលាកុមារមេត្រី

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីសាលាកុមារមេត្រី ក្នុងនោះសកម្មភាពអប់រំកុមារមានពិការភាពជាផ្នែកមួយនៃក្របខណ្ឌសកម្មភាពដែលមាន៦សមាសភាគគឺ ៖

- កុមារទាំងអស់បានចូលរៀន
- ការសិក្សាប្រកបដោយប្រសិទ្ធភាព
- សុខភាព សុវត្ថិភាព និងការការពារកុមារ
- ការឆ្លើយតបទៅនឹងយេនឌ័រ
- ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍
- ការគាំទ្រពីប្រព័ន្ធអប់រំ








## ឯកសារជំនួយសម្រាប់ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារមានពិការភាព

ឧបករណ៍មួយចំនួនត្រូវបានផលិតដើម្បីធ្វើការកំណត់អត្តសញ្ញាណកុមារមានពិការភាព ដោយបានកំណត់ប្រភេទពិការភាពជា៥ប្រភេទរួមមាន៖ ១.កុមារមានបញ្ហាចលនា ២.កុមារមានបញ្ហាស្តាប់ ៣.កុមារមានបញ្ហានិយាយ ៤.កុមារមានបញ្ហាមើល ៥.កុមារមានបញ្ហាខ្សោយបញ្ញា។



## គោលនយោបាយស្ដីពីការអប់រំបរិយាបន្ន និងផែនការសកម្មភាពស្ដីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២០២៣

- ធានាការកំណត់អត្តសញ្ញាណបឋម ការវាយតម្លៃ និងធ្វើអន្តរាគមន៍ទាន់ពេល
- ផ្ដល់សេវាអប់រំមានគុណភាពប្រកបដោយបរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិត
- ការសាងសមត្ថភាព និងលើកកម្ពស់ការអភិវឌ្ឍជំនាញដល់គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន
- លើកកម្ពស់ការយល់ដឹងនិងការចូលរួម






ផែនការសកម្មភាពស្ដីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២០២៣ បានដាក់ចេញឱ្យប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡាដើម្បីបង្កើនការចុះឈ្មោះចូលរៀនរបស់ជនស្ថិតនៅក្នុងសេចក្ដីត្រូវការពិសេស

## ស្ថិតិសិស្ស និស្សិតមានពិការភាព និងបុគ្គលិកមានពិការភាព

### តារាងខាងក្រោមបង្ហាញពីការសិក្សារបស់សិស្ស និសិត្សមានពិការភាពឆ្នាំសិក្សា ២០១៧-២០១៩

| ពិពណ៌នា | ចំនួនសាលា | ចំនួនសិស្សសរុប | ចំនួនសិស្សមានពិការភាព | ភាគរយ% |
|---|---|---|---|---|
| សាលាមត្តេយ្យ | ៧.១៨៨ | ៤៣១.៤១០ | ២.៥៤៦ | ០,៦ |
| បឋមសិក្សា | ៧.១៨៩ | ២.០២២.០៦១ | ៤៣.៣៤៤ | ០,២១ |
| អនុវិទ្យាល័យ | ១.២៣៧ | ៦៣១.១០១ | ៨.៩៤៨ | ១,១៤ |
| វិទ្យាល័យ | ៥១១ | ៣២២.០០០ | ៥.៤១៩ | ១,៦៨ |
| ឧត្តមសិក្សា | ១២១ | ២០៧.៤៣៤ | ៣៧ | ០,០១៧ |

(ប្រភព៖ បានមកពីក្រសួងអប់រំយុវជននិងកីឡា)

### ចំនួនបុគ្គលិកអប់រំទូទាំងប្រទេស

| ចំនួនបុគ្គលិកអប់រំ | ស្ត្រី | បុគ្គលិកអប់រំមានពិការភាព | ស្ត្រីមានពិការភាព |
|---|---|---|---|
| ១១៩.៣៦៨នាក់ | ៥៤.៣១៣នាក់ | ១.២៥២នាក់ | ៣៤២នាក់ |

### ចំនួនគ្រូដែលទទួលបានការបណ្តុះបណ្តាលអំពីការអប់រំបរិយាបន្ន

| គ្រូទទួលបានការបណ្តុះបណ្តាល | ស្ត្រី | គ្រូឧទ្ទេសថ្នាក់ជាតិ | ស្ត្រី |
|---|---|---|---|
| ៧.០៣៦នាក់ | ១.៣៤៥នាក់ | ៤០នាក់ | ១១នាក់ |

### ជនមានពិការភាពដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈគិតពីឆ្នាំ២០១៤-២០១៨

មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការទាំងពីរ បានបណ្តុះបណ្តាលសិស្សសរុបចំនួន ៦៦៣នាក់ (ស្រីចំនួន១៧២នាក់)។

| | | |
|---|---|---|
| មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាប (JSC) | សកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ | ចំនួន ៦៦៣នាក់ |
| | សិស្សដែលទៅបម្រើការងារ | ចំនួន ១១៨នាក់ |
| | សិស្សដែលទៅប្រកបមុខរបរ | ចំនួន ៨០នាក់ |
| មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ (JCIA) | សកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ | ចំនួន ២០១នាក់ |
| | សិស្សដែលទៅប្រកបមុខរបរ | ចំនួន ៣៧នាក់ |

# ករណីសិក្សា



សាលាគ្រួសារថ្មីជាសាលាគ-ថ្លង់ដំបូងបង្អស់ដែលបានបើកនៅឆ្នាំ១៩៩៧ដើម្បីផ្តល់ការសិក្សាអប់រំ និងគាំទ្រដល់កុមារគ-ថ្លង់ឲ្យចូលរួមក្នុងសង្គម។ សាលាអប់រំពិសេសសម្រាប់កុមារមានពិការភ្នែក និងគ-ថ្លង់ មានចំនួនប្រាំសាលា៖ ១).សាលារៀនកុមារគ-ថ្លង់ច្បារអំពៅ ២).សាលារៀនកុមារពិការភ្នែក និងគ-ថ្លង់ខេត្តកំពង់ចាម ៣).សាលារៀនកុមារពិការភ្នែក និងគ-ថ្លង់ខេត្តបាត់ដំបង ៤).សាលារៀនកុមារពិការភ្នែក និងគ-ថ្លង់ភ្នំពេញថ្មី ៥).សាលារៀនកុមារពិការភ្នែក និងគ-ថ្លង់ខេត្តសៀមរាប។ សាលាគ្រួសារថ្មី ត្រូវបានផ្ទេរទៅឲ្យរដ្ឋាភិបាលដោយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបង្កើតទៅជាប្រព័ន្ធអប់រំពិសេសសាធារណៈមួយនៅកម្ពុជា។



រាជរដ្ឋាភិបាលបានធ្វើសមាហរណកម្មបុគ្គលិកអង្គការដៃគូអភិវឌ្ឍនានាដែលបម្រើការងារវិស័យអប់រំ លើផ្នែកពិការភាពចំនួន២៧២នាក់ ស្រី១៤២នាក់ទៅក្នុងក្របខណ្ឌរដ្ឋ និងបានចេញប្រកាសប្រែក្លាយសាលារៀនកុមារពិការភ្នែក និងគ-ថ្លង់ទាំង៥សាខាទៅជាវិទ្យាល័យអប់រំពិសេស។ ការផ្ទេរនេះជាសាក្ខីកម្មនៃឆន្ទៈ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការអប់រំពិសេសដល់ជនមានពិការភាព និងធានាឲ្យបាននិរន្តរភាពនៃបទពិសោធ និងសមត្ថភាពអប់រំពិសេស។



# ទិសដៅយុទ្ធសាស្ត្រ ទី ៦

## លើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងការសម្តែងមតិ ទទួលព័ត៌មាន និងចូលរួមជីវភាពនយោបាយ







# សមិទ្ធផលសម្រេចបាន



សិទ្ធិក្នុងការសម្តែងមតិដោយសេរីមានធានាដោយឡែក នៅក្នុងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញដែលចែងថា "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។"

មាត្រា៣៥នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមនៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។"

## ការចូលរួមបោះឆ្នោតរបស់ជនមានពិការភាព

ឆ្លើយតបទៅនឹងការលើកកម្ពស់ការចូលរួមរបស់ជនមានពិការភាពក្នុងការសម្តែងមតិ ទទួលព័ត៌មាន និងចូលរួមជីវភាពនយោបាយ ជនមានពិការភាពជាច្រើនលើសលប់បានទៅចូលរួមបោះឆ្នោតស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឈរលើសិទ្ធិស្មើគ្នាជាមួយអ្នកដទៃហើយទទួលបានការធានាការការពារសិទ្ធិក្នុងការបោះឆ្នោតដោយសម្ងាត់គ្មានការបំភិតបំភ័យដែលជាការបង្ហាញអំពីឆន្ទៈដោយសេរីប្រកបដោយប្រជាធិបតេយ្យ។






តំណាងជនមានពិការភាពបានចូលរួមជាអ្នក សង្កេតការណ៍និងជួយ គ.ជ.ប ក្នុងការផ្តល់ការសម្របសម្រួលសមស្របសម្រាប់ជនមានពិការភាពមកកាន់ស្ថានីយបោះឆ្នោតនៅក្នុងសហគមន៍មូលដ្ឋាន។ នេះបង្ហាញពីការគាំទ្ររបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិសេរីភាពជនមានពិការភាពក្នុងការចូលរួមជីវភាពនយោបាយ។

## ស្ថិតិជនមានពិការភាពបានចុះឈ្មោះបោះឆ្នោត និងបានចូលរួមបោះឆ្នោត

**ចំនួនអ្នកចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ (គិតត្រឹមថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦)**

| អ្នកចុះឈ្មោះបោះឆ្នោត | សរុបចំនួន | ស្ត្រីចំនួន |
|---|---|---|
| ជនមានពិការភាពសរុប | ៨.៥៩៣ នាក់ | ២.៨៨៧ នាក់ |
| ជនមានពិការភាពដៃឆ្វេង | ២.៩៩២ នាក់ | ៧៧៨ នាក់ |
| ជនមានពិការភាពដៃស្តាំ | ៤.១៥២ នាក់ | ១.៣៩៥ នាក់ |
| ជនមានពិការភាពដៃទាំងសងខាង | ១.៤៤៩ នាក់ | ៧១៤ នាក់ |

**ចំនួនអ្នកចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៦ ឆ្នាំ២០១៨ (គិតត្រឹមថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧)**

| អ្នកចុះឈ្មោះបោះឆ្នោតថ្មី | សរុបចំនួន | ស្ត្រីចំនួន |
|---|---|---|
| ជនមានពិការភាពសរុប | ៥.៨៨០ នាក់ | |
| ជនមានពិការភាពដៃឆ្វេង | ២.៤២៨ នាក់ | ១.១៩៣ នាក់ |
| ជនមានពិការភាពដៃស្តាំ | ២.៥៣០ នាក់ | ១.២៥៨ នាក់ |
| ជនមានពិការភាពដៃទាំងសងខាង | ៧៤៥ នាក់ | ៤២៧ នាក់ |
| ជនមានពិការភាពជើងទាំងសងខាង | ៤៥ នាក់ | ១៤ នាក់ |
| ជនមានពិការភាពភ្នែកទាំងសងខាង | ១៣២ នាក់ | ៦១ នាក់ |

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីណែនាំលេខ១២៧២ គ.ជ.ប. ចុះ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រភេទនៃ អ្នកសុំចុះឈ្មោះបោះឆ្នោតដែលមានពិការភាពសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលយកជនមានពិការភាពឱ្យចូលធ្វើការជាមន្ត្រីរៀបចំការបោះឆ្នោត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានបុគ្គលិកមានពិការភាពចំនួន១៣នាក់កំពុងបម្រើការងារ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ១២៧២ គ.ជ.ប

សេចក្តីណែនាំ
ស្តីពី
ការកំណត់ប្រភេទនៃអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមានពិការភាព សម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧




## កិច្ចពិភាក្សាស្តីពីពិការភាព

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ សហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ក្រោមការគាំទ្រហិរញ្ញវត្ថុដោយរដ្ឋាភិបាលអូស្ត្រាលី បានរៀបចំកិច្ចពិភាក្សាស្តីពីពិការភាពចាប់ពីឆ្នាំ២០១៤ ដល់ ២០១៨ បានចំនួន៤៨ប្រធានបទ មានវាគ្មិនសរុបចំនួន ១៦២នាក់ ស្ត្រីចំនួន២៩នាក់ វាគ្មិនជាជនមានពិការភាព ចំនួន៥៩នាក់ អ្នកនយោបាយចំនួន៥៥នាក់ អង្គការជាតិ អន្តរជាតិចំនួន៤៨នាក់។

កិច្ចពិភាក្សាស្តីពីពិការភាពមានគោលបំណងបង្ហាញ អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលដើម្បីបង្កើន ការយល់ដឹងអំពីច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិ ជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ផែនការយុទ្ធសាស្ត្រ ជាតិស្តីពីពិការភាព និងកម្មវិធីឬសេវាកម្មដែលបម្រើផល ប្រយោជន៍ដល់ជនមានពិការភាព។














## ការទទួលបានព័ត៌មានសម្រាប់មនុស្សគ-ថ្លង់

ជនមានពិការភាពគ្រប់ប្រភេទនៅកម្ពុជាអាចទទួលព័ត៌មានគ្រប់មធ្យោបាយរួមបញ្ចូលទាំងការបកប្រែភាសាសញ្ញា នៅតាមស្ថានីយទូរទស្សន៍នានាទាំងក្នុងកម្មវិធីផ្សាយព្រឹត្តិការព័ត៌មានជាតិ និងអន្តរជាតិ។ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** តែងបានអំពាវនាវដល់គ្រប់ស្ថានីយទូរទស្សន៍ទាំងអស់នៅកម្ពុជាដាក់បញ្ចូលការបកប្រែភាសាសញ្ញាសម្រាប់មនុស្សគ-ថ្លង់ទៅក្នុងកម្មវិធីព័ត៌មានផ្សេងៗរបស់ខ្លួន។





| ល.រ | ស្ថានីយទូរទស្សន៍ | កម្មវិធី | ម៉ោង |
|---|---|---|---|
| ១ | ទូរទស្សន៍ជាតិកម្ពុជា (ទទក) | ព័ត៌មាននិងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ ប្រចាំថ្ងៃ សប្តាហ៍ និងឆ្នាំ | ១៩:០០-២០:០០ |
| ២ | ទូរទស្សន៍ព័ត៌មាន Fresh News | សរុបព័ត៌មានប្រចាំថ្ងៃ | ១៩:០០-២១:០០ |
| ៣ | ទូរទស្សន៍បាយ័ន | ព័ត៌មាន | ១៨:៣០-១៩:០០ |
| ៤ | ទូរទស្សន៍ BTV | ព័ត៌មាន | ១៩:០០-២០:០០ |
| ៥ | ទូរទស្សន៍អប្សរា (១១) | ព័ត៌មានអប្សរាព្រឹកនេះ | ០៦:០០-០៧:៣០ |
| ៦ | ទូរទស្សន៍រាជធានីភ្នំពេញ (TV3) | ព័ត៌មានប្រចាំថ្ងៃ | ១៩:០០-២០:០០ |
| ៧ | ទូរទស្សន៍ PNN | ព័ត៌មានពេលល្ងាច | ១៩:៥០-២០:៥០ |
| ៨ | ទូរទស្សន៍ អាស៊ីអាគ្នេយ៍ | ព័ត៌មានអរុណសួស្តីចុងសប្តាហ៍ | ០៧:០០-០៨:០០ |
| ៩ | ទូរទស្សន៍ CNC | ព័ត៌មានចុងសប្តាហ៍ពេលព្រឹក | ១០:៣០-១១:០០ |
| ១០ | ទូរទស្សន៍ខ្មែរ (ទទ៩) | ព័ត៌មាន | |
| ១១ | ទូរទស្សន៍ខ្សែកាប (CTV8) | ព័ត៌មាន | |

## ករណីសិក្សា : ការរៀបចំទិវាជនមានពិការភាពកម្ពុជានិងអន្តរជាតិពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨

| ឆ្នាំផ្សព្វផ្សាយ | កាលបរិច្ឆេទ | គណធិបតី | ទីកន្លែង | សមាសភាពចូលរួម | ប្រធានបទ |
|---|---|---|---|---|---|
| ២០១៤ | ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ជាតិលើកទី១៦និង អន្តរជាតិលើកទី៣២ | លោកជំទាវឧបនាយករដ្ឋមន្ត្រី **ម៉ែន សំអន** | វិទ្យាស្ថានជាតិអប់រំ | ១.៥០០នាក់ | ផ្តល់លទ្ធភាពអាចប្រើប្រាស់បាន រួមបញ្ចូលមុខរបរ ការងារ និងបច្ចេកវិទ្យា ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព |
| ២០១៥ | ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៤ ជាតិលើកទី១៧និង អន្តរជាតិលើកទី៣៣ | លោកជំទាវឧបនាយករដ្ឋមន្ត្រី **ម៉ែន សំអន** | វិទ្យាស្ថានជាតិអប់រំ | ១.៩០០នាក់ | រួមគ្នាបង្ករលក្ខណៈងាយស្រួលដល់ជនពិការ ដើម្បីបរិស្ថានគ្មានពិការភាព |
| ២០១៦ | ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៤ ជាតិលើកទី១៨និង អន្តរជាតិលើកទី៣៤ | សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | កោះពេជ្រ | ២.៧០០នាក់ | ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព |
| ២០១៧ | ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៤ ជាតិលើកទី១៩និង អន្តរជាតិលើកទី៣៥ | សម្តេចពិជ័យសេនា **ទៀ បាញ់** | កោះពេជ្រ | ២.៥០០នាក់ | ធ្វើឲ្យមានភាពរឹងមាំស្របនឹងសង្គមមួយមានសន្តិភាព សម្រាប់ទាំងអស់គ្នា |
| ២០១៨ | ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៤ ជាតិលើកទី២០និង អន្តរជាតិលើកទី៣៦ | ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** | កោះពេជ្រ | ២.៥០០នាក់ | លើកកម្ពស់សិទ្ធិជនពិការ ធានាដល់ការធ្វើបរិយាបន្ន និងសមភាព |





## ក្រុមការងារសកម្មភាពជនពិការក្រសួងទេសចរណ៍រៀបចំផ្សព្វផ្សាយការយល់ដឹងស្តីពីពិការភាពនៅកម្ពុជា

| ឆ្នាំផ្សព្វផ្សាយ | កាលបរិច្ឆេទ | រាជធានី-ខេត្ត | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ឆ្នាំ២០១៦ ចំនួន៣លើក | ១៩ កញ្ញា ២០១៦ | ព្រះសីហនុ | ៦០នាក់ |
| | ២៤ តុលា ២០១៦ | សៀមរាប | ៦០នាក់ |
| | ១៣ ធ្នូ ២០១៦ | ខេត្តកំពង់ចាម | ៦០នាក់ |
| ឆ្នាំ២០១៧ ចំនួន៦លើក | ០៩ មិថុនា ២០១៧ | នៅខេត្តកំពង់ធំ | ៦៥នាក់ |
| | ២៩ មិថុនា ២០១៧ | បាត់ដំបង | ៦៥នាក់ |
| | ០៩ សីហា ២០១៧ | មណ្ឌលគីរី | ៧០នាក់ |
| | ២៨ សីហា ២០១៧ | កោះកុង | ៧០នាក់ |
| | ០៧ វិច្ឆិកា ២០១៧ | បន្ទាយមានជ័យ | ១០៥នាក់ |
| | ១៣ វិច្ឆិកា ២០១៧ | ពោធិ៍សាត់ | ៩០នាក់ |
| ឆ្នាំ២០១៨ ចំនួន៤លើក | ២២ មីនា ២០១៨ | រតនគិរី | ៩០នាក់ |
| | ១០ មេសា ២០១៨ | កំពង់ស្ពឺ | ៩៦នាក់ |
| | ២២ ឧសភា ២០១៨ | តាកែវ | ៧០នាក់ |
| | ០៥ មិថុនា ២០១៨ | កំពង់ឆ្នាំង | ៨០នាក់ |
| **សរុប** | | **១៣ខេត្ត** | **១.៣៨៤នាក់** |






# ទិសដៅយុទ្ធសាស្ត្រ
# ទី៧





ធានាដល់ការចូលរួមសកម្មភាពសង្គម
រួមមានវប្បធម៌ សាសនា កីឡា សិល្បៈ
ការសម្រាកលំហែ និងសកម្មភាពផ្សេងៗទៀត



ការលើកទឹកចិត្តនិងការបង្កើនឱកាសដល់ជនមានពិការភាពគ្រប់ប្រភេទ ចូលរួមក្នុងសកម្មភាពសង្គមនានា ដើម្បីលើកកម្ពស់សក្តានុពលបញ្ញា ស្មារតី ជំនាញ និងទេពកោសល្យ តាមរយៈការចូលរួមក្នុងសកម្មភាពវប្បធម៌ សិល្បៈ និងកីឡាផ្សេងៗដូចជា៖ ការប្រគំតន្ត្រី ការប្រឡងចម្រៀង របាំ កីឡារត់ប្រណាំង រទេះរុញ និងដំណើរកម្សាន្តជាដើម។

# សមិទ្ធផលសម្រេចបាន

## ការចូលរួមសម្តែងសិល្បៈរបស់ជនមានពិការភាព

ការលើកកម្ពស់ការទទួលបាន ឧបករណ៍និងសម្ភារៈផ្សេងៗ ក្នុងវិស័យវប្បធម៌ តាមទ្រង់ទ្រាយដែលជនមានពិការភាពអាចទទួលយកបាន ត្រូវបានផ្តល់ដោយប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដើម្បីបង្កើនឱកាសដល់ជនមានពិការភាពរៀបចំ ចាត់ចែង អភិវឌ្ឍ និងចូលរួមជាសាធារណៈនូវគ្រប់កម្រិតក្នុងសកម្មភាពវប្បធម៌និងសិល្បៈ។











សិល្បៈការិនីគ-ថ្លង់នៃអង្គការគ្រួសារថ្មី
សម្តែងរបាំជូនពរក្នុងទិវាមនុស្សគ-ថ្លង់ឆ្នាំ២០១៦



កម្ពុជាបានដឹកនាំយុវជនមានពិការភាព ចូលរួមការប្រកួតប្រជែងព័ត៌មានវិទ្យារបស់យុវជនមានពិការភាពនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ចំនួន៥លើក ទទួលបានមេដាយមាស ចំនួន៧គ្រឿង មេដាយប្រាក់ ចំនួន៧គ្រឿង និងមេដាយសំរឹទ្ធ ចំនួន៥គ្រឿង។

ការប្រកួតប្រជែងព័ត៌មានវិទ្យារបស់យុវជនមានពិការភាពផ្តោតលើវិញ្ញាសាសំខាន់ៗចំនួនបួន៖

១. វិញ្ញាសា eDesign
២. វិញ្ញាសា eCreative
៣. វិញ្ញាសា eLifeMap
៤. វិញ្ញាសា eTool ។





# ការចូលរួមប្រកួតប្រជែងរបស់យុវជនមានពិការភាពកម្ពុជា លើផ្នែកព័ត៌មានវិទ្យាកម្រិតអន្តរជាតិ




នៅឆ្នាំ២០១៤អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការបានដឹកនាំយុវជនមានពិការភាពចំនួន៦រូប ទៅប្រកួតប្រជែងផ្នែកព័ត៌មានវិទ្យា នៅទីក្រុងប៊ូសាន សាធារណៈរដ្ឋកូរ៉េ ជាលទ្ធផលកម្ពុជាទទួលបានមេដាយច្រើនជាងគេរហូតដល់ ១៥គ្រឿង (មាស៧គ្រឿង ប្រាក់៧គ្រឿង និងសំរឹទ្ធ១គ្រឿង)។

ជាមោទនភាព យុវជនមានពិការភាពកម្ពុជាមួយរូបឈ្មោះ កែវ ច័ន្ទឧត្តម បានទទួលជ័យលាភីមេដាយ ជើងឯក Global IT Leader ឆ្នាំ២០១៤ ប្រចាំតំបន់អាស៊ាន។ យុវជនមានពិការភាពកម្ពុជាទាំងរូប៦នេះ បានទទួលការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា និងអនុញ្ញាតឱ្យចូលសម្តែងការគួរសមជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងទទួលបានការផ្តល់ក្របខណ្ឌរដ្ឋចូលបម្រើការងារនៅក្រុមប្រឹក្សាសកម្មភាពជនពិការ។




អនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ស្តីពីកំណត់ការផ្តល់ប្រាក់រង្វាន់ដល់ជនពិការដែលទទួលបានជ័យលាភីពីការប្រកួតប្រជែងជំនាញ និងការប្រកួតកីឡាស៊ើស្បាល់អូឡាំពិកក្នុងបំណងលើកកម្ពស់សិទ្ធិរបស់ជនមានពិការភាព និងលើកទឹកចិត្តក្នុងការចូលរួមប្រកួតប្រជែងមុខជំនាញនិងការប្រកួតកីឡាស៊ើស្បាល់អូឡាំពិកជាលក្ខណៈជាតិ និងអន្តរជាតិដោយស្មើភាពដូចអ្នកដទៃ និងការប្រើប្រាស់សក្តានុពលច្នៃប្រឌិត និងសតិបញ្ញារបស់ពួកគេ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្តល់ប្រាក់ឧបត្ថម្ភចំពោះជ័យលាភីជនពិការ
ក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាស៊ើស្បាល់អូឡាំពិក
និងប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក គ្រូបង្វឹកជំនួយ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិកសម្រាប់ជនពិការ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៥



ការប្រណាំងរទេះច្រវ៉ាក់

វិធានការសមស្របនានាដើម្បីឲ្យជនមានពិការភាពទទួលបានសិទ្ធិពេញលេញក្នុងសកម្មភាពកីឡាត្រូវបានអនុវត្តយ៉ាងពេញលេញក្នុងទស្សនៈជួយឱ្យជនមានពិការភាពបានចូលរួមជាមួយជនមិនមានពិការភាព។

ជាក់ស្តែងរាជរដ្ឋាភិបាលបានជំរុញ និងលើកស្ទួយការចូលរួមរបស់ជនមានពិការភាពបានយ៉ាងខ្លាំងក្លាក្នុងសកម្មភាពកីឡាជាសាធារណៈគ្រប់កម្រិតទាំងអស់។ ទីកន្លែងសម្រាប់លេងកីឡាត្រូវបានកែលម្អនិងផ្តល់ភាពងាយស្រួលដែលជនមានពិការភាពអាចលេងកម្សាន្ត រួមទាំងការលើកទឹកចិត្តឲ្យមានការប្រកួតប្រជែងកីឡាបែបបរិយាបន្ន។

ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំដំណើរកម្សាន្តជារៀងរាល់ឆ្នាំដល់កុមារពិការភ្នែក និងគ-ថ្លង់ ទៅតាមតំបន់ទេសចរណ៍នានា នៃព្រះរាជាណាចក្រកម្ពុជាក្នុងទិសដៅអភិវឌ្ឍបញ្ញា និងគំនិតច្នៃប្រឌិតរបស់ជនមានពិការភាពដើម្បីទទួលបានផលប្រយោជន៍ និងភាពសម្បូរបែបរបស់សង្គម។








ការរត់ប្រណាំងរបស់ជនពិការភ្នែក

## គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា

គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិកសម្រាប់ជនមានពិការភាពកម្ពុជា។ ជនមានពិការភាពបានចូលរួមការប្រកួតជាខ្នាតអន្តរជាតិបានចំនួន២៤លើកនិងបានទទួលមេដាយសរុបចំនួន១៥៩គ្រឿង ក្នុងនោះមេដាយមាសចំនួន២២គ្រឿង មេដាយប្រាក់៧៨គ្រឿង មេដាយសំរិទ្ធ៥៩គ្រឿង។




## គណៈកម្មាធិការជាតិស៉ៀស្យាល់អូឡាំពិកកម្ពុជា



គណៈកម្មាធិការជាតិស៉ៀស្យាល់អូឡាំពិកកម្ពុជាបានបង្កើតឡើងនៅថ្ងៃទី១ ខែសីហា ឆ្នាំ ២០០៥ នៅក្នុងអង្គប្រជុំលើកទី១របស់គ្រូបង្វឹកកីឡាសម្រាប់ជនបញ្ញាខ្សោយនៅពហុកីឡាដ្ឋានជាតិអូឡាំពិក។ តាមរយៈគណៈកម្មាធិការនេះ កម្ពុជាបានបញ្ជូនជនមានបញ្ហាខ្សោយសតិបញ្ញាទៅចូលរួមការប្រកួតជាលក្ខណៈអន្តរជាតិបានចំនួន១២លើក ថ្នាក់អនុតំបន់មេគង្គ ចំនួន៧លើក ថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន១លើក ថ្នាក់តំបន់អាស៊ីអាគ្នេយ៍ចំនួន១លើក ទទួលមេដាយសរុបចំនួន៧៦គ្រឿង មេដាយមាស២៣គ្រឿង មេដាយប្រាក់៤៩គ្រឿង និងមេដាយសំរិទ្ធ៤គ្រឿង។





## ករណីសិក្សា :

## ការផ្តល់ប្រាក់រង្វាន់ដល់ជនមានពិការភាពដែលទទួលបានជ័យលាភី



លោកតាព្រឹទ្ធាចារ្យ **ប្រាជ្ញ ឈួន** ជាជនពិការភ្នែកមានជំនាញខាងផ្នែកសិល្បៈចាប៉ីដងវែងត្រូវបាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈផ្តល់ជូននូវគោរមងារជាភិរម្យវោហារ **ប្រាជ្ញ ឈួន** ។



លោកតាព្រឹទ្ធាចារ្យ **គង់ ណៃ** ជាជនពិការភ្នែកមានជំនាញខាងផ្នែកសិល្បៈចាប៉ីដងវែង ត្រូវបានក្រសួងវប្បធម៌និងវិចិត្រសិល្បៈផ្តល់ជូននូវគោរមងារថ្នាក់ជាតិជាកោសល្យវោហារ **គង់ ណៃ** ជាពិសេសលោកតាទទួលបាននូវពានរង្វាន់សិល្បៈវប្បធម៌ឆ្នាំ២០១៧ ក្រុងហ្វុគុអូកានៃប្រទេសជប៉ុន។

# ទិសដៅយុទ្ធសាស្ត្រ

# ទី៨

## អភិវឌ្ឍនិងកែសម្រួលឲ្យមានលក្ខណៈងាយស្រួលក្នុងការ ប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូន បម្រើជាសាធារណៈ ចំណេះដឹង ព័ត៌មាន និង ទំនាក់ទំនងចំពោះជនមានពិការភាព







រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខៈ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ តាមរយៈក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជនដែលមានគោលបំណងបន្ថែម ការយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់ទាំងអស់គ្នា រួមទាំងជនមានពិការភាព ចាស់ជរា និងកុមារ។ ការអភិវឌ្ឍ និងកែសម្រួលឱ្យមានលក្ខណៈងាយស្រួល ក្នុងការប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនព័ត៌មាន និងការទំនាក់ទំនងគឺជាវិធានការរបស់រាជរដ្ឋាភិបាលក្នុងការជំរុញឱ្យមានការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។



# សមិទ្ធផលសម្រេចបាន

## គោលនយោបាយ និងលិខិតបទដ្ឋានអំពីការបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព

ប្រកាសអន្តរក្រសួងលេខ២៤៨ សអយ.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ស្តីពី "បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពចំពោះគម្រោងសាងសង់និងការកែសម្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដូចជាសំណង់ អគារ និងទីកន្លែងសាធារណៈនានា" ត្រូវបានប្រកាសដាក់អោយអនុវត្ត ។



## ករណីសិក្សា :

### ការបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព ស្ត្រីមានផ្ទៃពោះ និងជនចាស់ជរា

ក្រសួងមហាផ្ទៃបានជម្រាបទៅដល់អភិបាលរាជធានី/ខេត្ត តាមរយៈ ស.ជ.ណ លេខ៥៤០ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការដាក់បញ្ចូលការ គិតគូរដល់ជនមានពិការភាព ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឱ្យមានការបង្កលក្ខណៈងាយស្រួល ដល់ជនមានពិការភាពនូវការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅមូលដ្ឋាន។





ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញសេចក្តីជូនដំណឹងលេខ:៣០៧៦ ដនស/អរប ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចូលរួមកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការដល់អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ ប្រធានគណៈកម្មការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់រាជធានី-ខេត្ត ដោយស្នើសុំ ចាត់ចែងឱ្យមានហេដ្ឋារចនាសម្ព័ន្ធទីកន្លែងបរិក្ខារ និងសេវាសម្រាប់ជនមានពិការភាព គ្រប់ប្រភេទដូចជា ការរៀបចំផ្លូវជម្រាល ផ្លូវដើរ ជណ្តើរ បង្កាន់ដៃសុវត្ថិភាព ស្លាកសញ្ញា និងបរិក្ខារជំនួយសុវត្ថិភាពផ្សេងៗ សម្រាប់ជនមានពិការភាព ចំពោះរាល់គម្រោងអភិវឌ្ឍនានា។

ក្រសួងធម្មការ និងសាសនាបានដាក់ចេញនូវសេចក្តីប្រគេនជូនដំណឹង លេខ០១/១៨ ក.ធ.ស.ស.ជ.ណ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ស្តីពីការស្នើសុំ “ចំពោះរាល់ការសាងសង់អាគារថ្មីដូចជាមន្ទីរធម្មការ និងសាសនា ព្រះវិហារស៊ីវ៉ាវសាលាឆាន់ បន្ទប់ទឹក (វេច្ចកុដិ) ឬសំណង់ផ្សេងៗ ត្រូវធ្វើជម្រាលសម្រាប់ជនមានពិការភាព ដើម្បីឱ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរឡើងចុះក្នុងការប្រារព្ធពិធីផ្សេងៗ”។





# ទិសដៅយុទ្ធសាស្ត្រ

# ទី ៩

## ធានាសមភាពយេនឌ័រ និងការលើកកម្ពស់ សមត្ថភាពស្ត្រីនិងកុមារមានពិការភាព






កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ នៅឆ្នាំ១៩៩២ និងពិធីសារតាមជម្រើសនៃអនុសញ្ញានេះនៅឆ្នាំ២០១០។ ក្រសួងកិច្ចការនារីបានរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលចំនួន៥វគ្គ នៅរាជធានីភ្នំពេញចំនួន២វគ្គ និងចំនួន៣វគ្គទៀតនៅ ខេត្តព្រះសីហនុ មណ្ឌលគិរី និងសៀមរាប។

# សមិទ្ធផលសម្រេចបាន

## យន្តការសម្របសម្រួល និងផ្តល់សេវាគាំពារស្ត្រីនិងកុមារមានពិការភាព



- គាំទ្រគោលការណ៍ទាំង១៦ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ។
- ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី២០១៤-២០១៨ (នារីរតនៈជំហានទី៤) បានផ្តោតយកចិត្តទុកដាក់លើស្ត្រីមានពិការភាព។
- ស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រនិងពិការភាព ការបញ្ជ្រាបពិការភាពទៅក្នុងវិស័យច្បាប់គោលនយោបាយ និងផែនការតាមស្ថាប័ន និងសង្គមស៊ីវិល។
- សិក្ខាសាលាចំនួន៥លើកស្តីពីការលើកកម្ពស់កិច្ចការពារជនមានពិការភាព និងលុបបំបាត់ការរើសអើងដើម្បីពង្រឹងសមត្ថភាពបង្កើនការយល់ដឹងនិងកំណត់វិធានការណ៍ដោះស្រាយ។
- អង្គការតំណាងស្ត្រីមានពិការចំនួន៩ ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងកុមារមានពិការភាពនៅសហគមន៍។

## ករណីសិក្សា :

## ការបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព ស្ត្រីមានផ្ទៃពោះ និងជនចាស់ជរា



ស្ត្រីដែលមានពិការភាពរងនូវអំពើហិង្សាផ្លូវចិត្តផ្លូវកាយ និងផ្លូវភេទច្រើនជាងស្ត្រីដែលមិនមានពិការភាព។ ពួកគាត់ងាយនឹងត្រូវគេប្រមាថ សំឡុត ធ្វើបាបផ្លូវកាយ និងផ្លូវភេទ ហើយមិនអាចគេចចេញពីស្ថានភាពដោយសារកត្តារាំងមួយចំនួនដែលគាត់ប្រឈម។ ស្ត្រីមានពិការភាពមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ និងអំណាចតិចជាងស្ត្រីដែលមិនមានពិការភាព។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ក្នុងការគាំទ្រសមភាពយេនឌ័រ និងលើកកម្ពស់ស្ត្រីនិងកុមារមានពិការភាព។ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល អង្គការតំណាងជនមានពិការភាពបានចូលរួមចំណែកក្នុងការអនុវត្តទិសដៅទី៩ របស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ក្នុងការគាំទ្រនិងផ្តល់ភាពអង់អាចដល់ស្ត្រី និងកុមារមានពិការភាពជាក់ស្តែង អង្គការសេវាកម្មអភិវឌ្ឍន៍ជនមានពិការភាពខេត្តពោធិសាត់ បានអនុវត្តកម្មវិធីកសាងសមត្ថភាពស្ត្រីមានពិការភាពក្នុងការក្លាយជាអ្នកដឹកនាំ ការបង្កើនសកម្មភាពប្រាក់ចំណូលដើម្បីចូលរួមពេញលេញនៅក្នុងសង្គម និងសេដ្ឋកិច្ចគ្រួសារ។





# ទិសដៅយុទ្ធសាស្ត្រ

# ទី១០










## ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយថ្នាក់អន្តរជាតិ ថ្នាក់អន្តរតំបន់ ថ្នាក់តំបន់ ថ្នាក់អនុតំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ




ទន្ទឹមនឹងការខិតខំប្រឹងប្រែងតាមរយៈការបង្កើតច្បាប់គោលនយោបាយផែនការយុទ្ធសាស្ត្រការលើកកម្ពស់ការយល់ដឹងនិងការអនុវត្តរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមគាំទ្រនិងអនុវត្តសន្ធិសញ្ញាអនុសញ្ញា និងគោលការណ៍ជាសកលទាក់ទងទៅនឹងពិការភាព

# សមិទ្ធផលសម្រេចបាន

## គាំទ្រនិងអនុវត្តសន្ធិសញ្ញា អនុសញ្ញា និងគោលការណ៍ជាសកលទាក់ទងទៅនឹងពិការភាព

- បានអនុម័តនិងអនុវត្តលើទសវត្សជនមានពិការភាពប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ២០១៣-២០២២ និងយុទ្ធសាស្ត្រ អ៊ីនឈាន់ **“ធ្វើឱ្យសិទ្ធិក្លាយជាការពិត”**

- បានផ្តល់សច្ចាប័ននិងអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ចូលជាធរមានសម្រាប់កម្ពុជានៅថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៣។









រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានអន្តរជាតិទទួលស្គាល់ជាប្រទេសគំរូក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកក្នុងការអនុវត្តយ៉ាងមានប្រសិទ្ធិភាពនៃអនុសញ្ញាសិទ្ធិជនមានពិការភាព ទសវត្សជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាពិត"។

## បណ្តាញកម្មវិធីស្តារលទ្ធភាពពលកម្មនៅសហគមន៍ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនិងពិភពលោក

រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមកិច្ចសហប្រតិបត្តិការជាអន្តរជាតិលើវិស័យពិការភាពដោយបានចូលជាសមាជិក៖

- បណ្តាញកម្មវិធីស្តារលទ្ធភាពពលកម្មនៅសហគមន៍ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងពិភពលោក
- កម្មវិធីស្តារលទ្ធភាពពលកម្មអន្តរជាតិ
- សហគ្រិនភាពជនមានពិការភាពប្រចាំសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។





## គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក

"ពិការភាពគឺជាផ្នែកអាទិភាពមួយរបស់រដ្ឋាភិបាលកម្ពុជា។ ប្រទេសកម្ពុជាចាត់ទុកសង្គមស៊ីវិលវិស័យឯកជន អង្គការជនពិការ ដៃគូអភិវឌ្ឍន៍គឺជាដៃគូសហប្រតិបត្តិការដ៏ល្អក្នុងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនមានពិការ"។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាពមានសារៈសំខាន់ បច្ចុប្បន្នយើងបានរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មីឆ្នាំ២០១៩-២០២៣ ដើម្បីផ្តោតលើការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការលើកកម្ពស់ការងារនិងការងារសមរម្យសម្រាប់ជនមានពិការភាពដើម្បីធានាជីវភាពរបស់ពួកគេប្រសើរឡើងនិងបង្កើនឯករាជ្យភាពរបស់ពួកគេ។

កម្ពុជាបានប្តេជ្ញាចិត្តនិងធ្វើដំណើរយ៉ាងស្វាហាប់ក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ជាពិសេសទសវត្សជនពិការប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់"ធ្វើឱ្យសិទ្ធិក្លាយជាការពិត"សំដៅជំរុញវិស័យពិការភាពឱ្យដំណើរការទៅកាន់តែល្អប្រសើរឡើង ស្របតាមស្ថានភាពវិវត្តនៃកម្ពុជា។ ជាក់ស្តែងកម្ពុជា បានចាត់ទុកវិស័យពិការភាពជាការងារអាទិភាពនៅក្នុងវិស័យអាទិភាពសំខាន់ៗដទៃទៀត ដោយបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។









## ក្រុមការងារសកម្មភាពជនពិការក្រសួង-ស្ថាប័ន ដែលបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយការងារពិការភាព

ក្រសួង-ស្ថាប័នចំនួន២០បានបង្កើតក្រុមការងារសកម្មភាពជនពិការដែលជាយន្តការសម្របសម្រួល និងពិគ្រោះយោបល់លើបញ្ហាពិការភាពនៅតាមក្រសួង-ស្ថាប័នរដ្ឋ។ ក្រុមប្រឹក្សាសកម្មភាពជនពិការទាំងថ្នាក់រាជធានី-ខេត្តចំនួន ២៤ បានដើរតួយ៉ាងសំខាន់ជាយន្តការថ្នាក់ក្រោមជាតិដោះស្រាយបញ្ហាពិការភាពនៅថ្នាក់មូលដ្ឋាន។


ក្រសួងព័ត៌មាន


ក្រសួងអប់រំ យុវជន និងកីឡា


ក្រសួងកិច្ចការនារី


ទីស្តីការគណៈរដ្ឋមន្ត្រី


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


ក្រសួងទេសចរណ៍


ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ


ក្រសួងផែនការ


ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ


ក្រសួងអភិវឌ្ឍន៍ជនបទ


ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី-ខេត្ត ដែលបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយការងារពិការភាព


រាជធានីភ្នំពេញ


ខេត្តកណ្ដាល


ខេត្តរតនៈគីរី


ខេត្តកំពង់ឆ្នាំង


ខេត្តកែប


ខេត្តកំពង់ធំ


ខេត្តតាកែវ


ខេត្តបន្ទាយមានជ័យ


ខេត្តសៀមរាប


ខេត្តកំពង់ស្ពឺ


ខេត្តប៉ៃលិន


ខេត្តស្ទឹងត្រែង


ខេត្តពោធិ៍សាត់


ខេត្តព្រះសីហនុ


ខេត្តកោះកុង


ខេត្តក្រចេះ


ខេត្តកំពត


ខេត្តឧត្តរមានជ័យ


ខេត្តកំពង់ចាម

សហការឧបត្ថម្ភការអនុវត្ត
ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨
ដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការដោយ៖

Australian Aid

UNDP
Empowered lives.
Resilient nations.









## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ


: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ

: +៨៥៥-២៣-៧២៧-៤២៨

: +៨៥៥-២៣-៧២៧-៤២៦

: info@dac.org.kh

: ក្រុមប្រឹក្សាសកម្មភាពជនពិការ-Disability Action Council

: www.dac.org.kh